Australian Government
Services Australia

KHMER

# myGov app

## ការចូលប្រើ myGov មានសុវត្ថិភាព និងងាយស្រួលនៅលើ ស្មាតហ្វូនរបស់អ្នក។

ជាមួយនឹង myGov app វា៖

- ងាយចុះឈ្មោះចូល
- ងាយស្រួលមើល និងគ្រប់គ្រងប្រអប់សារចូល myGov Inbox (ប្រអប់សារចូល) របស់អ្នក
- ចូលប្រើបានលឿនទៅក្នុងសេវាកម្មនានាដែលបានភ្ជាប់។

វាក៏មាន digital wallet ដើម្បីស្តុកទុកដោយសុវត្ថិភាពនូវវិញ្ញាបនបត្រ និងកាតឌីជីថលរដ្ឋាភិបាល មួយចំនួនផងដែរ។

## ទាញយក និងរៀបចំបង្កើត app

អ្នកត្រូវការគណនី myGov ដើម្បីរៀបចំបង្កើត app។ ប្រសិនបើអ្នកមិនមានគណនីទេ សូមបង្កើតវានៅឯ **my.gov.au**

### ការទាញយក app

ស្វែងរក Australian Government myGov app ផ្លូវការនៅក្នុង៖

- Apple App Store
- Google Play.

app គឺទាញយក និងប្រើប្រាស់ដោយឥតគិតថ្លៃ។

### ការរៀបចំបង្កើត app

នៅពេលអ្នកបានទាញយក app ហើយ សូមធ្វើតាម 4 ជំហានទាំងនេះ៖

1. បើក app និងជ្រើសរើស **Sign in**។
2. អានលក្ខខណ្ឌនៃការប្រើប្រាស់ និងសេចក្តីជូនដំណឹងពីឯកជនភាព។ ប្រសិនបើអ្នកយល់ និងយល់ព្រមទៅនឹងលក្ខខណ្ឌនៃការប្រើប្រាស់របស់ myGov, សូមជ្រើសរើស **I Accept**។
3. ចុះឈ្មោះចូលទៅក្នុងគណនី myGov របស់អ្នក។ អ្នកនឹងប្រើប្រាស់ណាមួយខាងក្រោម៖
    - ព័ត៌មានលម្អិតចុះឈ្មោះចូលនៃ myGov របស់អ្នក (ឈ្មោះអ្នកប្រើប្រាស់ ពាក្យសម្ងាត់ និងបញ្ចូលកូដសន្តិសុខ ឬឆ្លើយសំណួរសម្ងាត់)
    - myGovID Digital Identity របស់អ្នក ប្រសិនបើអ្នកបានបង្កើត Digital Identity របស់អ្នក ដោយប្រើឯកសារអត្តសញ្ញាណអូស្ត្រាលីរបស់អ្នក។
4. បង្កើត myGov app PIN (លេខសម្គាល់អត្តសញ្ញាណផ្ទាល់ខ្លួន) និងកំណត់ជម្រើសចុះឈ្មោះចូលរបស់អ្នក។ ប្រសិនបើអ្នកបានរៀបចំបង្កើតការទទួលស្គាល់ស្នាមម្រាមដៃ ឬការទទួលស្គាល់មុខនៅលើស្មាតហ្វូន របស់អ្នក នោះអ្នកនឹងត្រូវបានសួរថាតើអ្នកផ្តល់ការអនុញ្ញាតឱ្យប្រើវាដើម្បីចុះឈ្មោះចូល ឬអត់។

### បទប្បញ្ញត្តិសម្រាប់ myGov app PIN របស់អ្នក

PIN របស់អ្នកត្រូវតែមានប្រវែង 6 ខ្ទង់។ វាមិនអាច៖

- លេខដូចគ្នាដដែលៗលើសពី 5 ដងទេ ឧទាហរណ៍ 444444

- គូនៃលេខដដែលៗ ឧទាហរណ៍ 010101, 121212
- ប្រើលេខដែលស្ថិតនៅតាមលំដាប់ ឧទាហរណ៍ 123456, 987654។

កុំកំណត់ **PIN** ដែលងាយស្រួលឱ្យមនុស្សទាយបាន ឧទាហរណ៍ ថ្ងៃខែឆ្នាំកំណើតរបស់អ្នក។ យើងណែនាំឱ្យ myGov app PIN របស់អ្នកខុសពី **PINs** ដទៃទៀតដែលអ្នកប្រើប្រាស់។

## ប្រើ myGov app

### មើល និងគ្រប់គ្រងសារ myGov Inbox (ប្រអប់សារចូល)

អ្នកអាចៈ

- មើល ស្វែងរក និងលុបកសារ inbox របស់អ្នក
- បង្កើតសឺមី និងផ្លាស់ទីកន្លែងសារនានាក្នុងចំណោមសារទាំងនោះ។

### ចូលប្រើ និងគ្រប់គ្រងសេវាកម្មនានាដែលបានភ្ជាប់របស់អ្នក

ប្រើ app របស់អ្នកដើម្បីចូលប្រើ myGov សេវាកម្មនានាដែលបានភ្ជាប់របស់អ្នកបានលឿន និងមានសុវត្ថិភាព។ អ្នកអាចភ្ជាប់ និងដកការភ្ជាប់ពីសេវាកម្មនានានៅក្នុង app បាន។

### ស្តុកទុក និងចូលប្រើធាតុនានាដែលនៅក្នុង myGov wallet (វ៉ាលីតឌីជីថល) របស់អ្នក

wallet ឌីជីថលគឺជាកន្លែងមួយដែលស្តុកទុកវិញ្ញាបនបត្រ និងកាតឌីជីថលរដ្ឋាភិបាលមួយចំនួន បានសុវត្ថិភាព។ ធាតុនានាដែលអ្នកអាចបញ្ចូល អាស្រ័យលើសេវាកម្មណាខ្លះដែលអ្នកបានភ្ជាប់ និងកាលៈទេសៈរបស់អ្នក។

អ្នកអាចបញ្ចូលធាតុទាំងនេះៈ

- កាត Medicare
- កាតសម្បទាន Centrelink និងកាតថែទាំសុខភាព។

នៅក្នុងពេលអនាគត អ្នកនឹងអាចបញ្ចូលធាតុច្រើនទៀតបាន។

ជួនកាលវាអាចចំណាយពេលខ្លះនៅមុនពេលអ្នកផ្តល់សេវាទាំងអស់ត្រៀមខ្លួនរួចរាល់ដើម្បីទទួលយកកាត ឌីជីថលទាំងអស់។ ក៏ជាគំនិតល្អមួយផងដែរដែលអ្នកមានកាតជារូបវ័ន្តនៅជាមួយអ្នក។

ធាតុនានាដែលនៅក្នុង wallet មានកូដ QR code(កូដឆ្លើយតបលឿន) នៅលើធាតុទាំងនោះ។ អ្នកផ្តល់សេវាអាចស្កេនកូដនេះដើម្បីពិនិត្យមើលថាធាតុនោះត្រឹមត្រូវ និងមានសុពលភាព។ មុខងារសន្តិសុខនេះជួយការពារឯកសាររបស់អ្នកពីការបោកបន្លំ និងការលួច។

### ផ្លាស់ប្តូរការកំណត់គណនី myGov របស់អ្នក

អ្នកអាចមើល និងផ្លាស់ប្តូរការកំណត់គណនីមួយចំនួននៅក្នុង app របស់អ្នក។

#### ព័ត៌មានលម្អិតគណនី

អ្នកអាចៈ

- ជ្រើសរើសឈ្មោះដែលពេញចិត្តរបស់អ្នក
- មើលប្រវត្តិគណនី myGov របស់អ្នក
- បិទគណនី myGov របស់អ្នក។

### ជម្រើសក្នុងការចុះឈ្មោះចូល

ផ្លាស់ប្តូរជម្រើសក្នុងការចុះឈ្មោះចូល រួមមាន៖

- myGov app PIN របស់អ្នក
- ការទទួលស្គាល់ស្នាមម្រាមដៃ ឬការទទួលស្គាល់មុខ។

### សេចក្តីជូនដំណឹង

អ្នកអាចផ្លាស់ប្តូរសេចក្តីជូនដំណឹងរបស់អ្នក រួមមាន៖

- បើក app សេចក្តីជូនដំណឹងរុញ
- ជ្រើសរើសរបៀបដែលអ្នកទទួលបានសេចក្តីជូនដំណឹងក្នុង inbox
- បង្ហាញឈ្មោះសេវាកម្មនៅក្នុងសេចក្តីជូនដំណឹង inbox របស់អ្នក។

ប្រសិនបើអ្នកជ្រើសរើសដើម្បីទទួលបានសេចក្តីជូនដំណឹងរុញ នោះអ្នកនឹងត្រូវការបើកសេចក្តីជូនដំណឹង នៅក្នុងការកំណត់ស្មាតហ្វូនរបស់អ្នក។ ប្រសិនបើអ្នកបិទសេចក្តីជូនដំណឹងទាំងនោះនៅក្នុងការកំណត់ ឧបករណ៍របស់អ្នក នោះអ្នកនឹងត្រូវការអាប់ដេតចំណង់ចំណូលចិត្តនៃសេចក្តីជូនដំណឹងរបស់អ្នក នៅក្នុង app របស់អ្នកផងដែរ។

## ទទួលបានជំនួយជាមួយនឹង app

សម្រាប់ឱ្យ app របស់អ្នកដំណើរការបានល្អបំផុត សូមទាញយកការអាប់ដេតឱ្យបានលឿន ដែលអាចធ្វើទៅបាននៅពេលមានការអាប់ដេត។ អ្នកអាចរៀបចំបង្កើតការអាប់ដេតដោយស្វ័យប្រវត្តិសម្រាប់ស្មាតហ្វូនរបស់អ្នក។

អ្នកអាចស្វែងរកជំនួយជាមួយនឹងកិច្ចការជាក់លាក់មួយចំនួននៅក្នុង app ដូចជាការបញ្ចូលធាតុ នានាទៅក្នុង wallet របស់អ្នក ឬរបៀបផ្លាស់ប្តូរ myGov app PIN របស់អ្នក។

### ប្រសិនបើ app របស់អ្នកមិនដំណើរការដូចបានរំពឹងទុក

អ្នកអាច៖

- បិទ app និងបើកវាម្តងទៀត
- បិទឧបករណ៍របស់អ្នក ហើយបន្ទាប់មកបើកវាវិញ
- លុប ហើយបន្ទប់មកទាញយក app ម្តងទៀត។

ប្រសិនបើអ្នកលុប និងទាញយក app នោះអ្នកនឹងត្រូវការរៀបចំបង្កើត app របស់អ្នកម្តងទៀត។

### ប្រសិនបើឧបករណ៍របស់អ្នកប៉ះទង្គិច ឬជាប់គាំង

អ្នកគួរតែបិទ និងបើកឧបករណ៍របស់អ្នក រួចពិនិត្យមើលសញ្ញា ឬការភ្ជាប់អ៊ីនធឺណិតឥតខ្សែរបស់អ្នក។

### ប្រសិនបើអ្នកបានភ្លេច myGov app PIN របស់អ្នក

អ្នកអាចកំណត់ឡើងវិញនូវ myGov app PIN របស់អ្នក ប្រសិនបើអ្នកបានភ្លេចវា។

1. ជ្រើសរើស Forgot PIN នៅលើអេក្រង់ចុះឈ្មោះចូល myGov។
2. ចុះឈ មោះចូលទៅក្នុងគណនី myGov របស់អ្នក។ អ្នកនឹងប្រើប្រាស់ណាមួយខាងក្រោម៖
    - ព័ត៌មានលម្អិតចុះឈ្មោះចូលនៃ myGov របស់អ្នក (ឈ្មោះអ្នកប្រើប្រាស់ ពាក្យសម្ងាត់ និងបញ្ចូលកូដសន្តិសុខ ឬឆ្លើយសំណួរសម្ងាត់)

- myGovID Digital Identity របស់អ្នក ប្រសិនបើអ្នកបានបង្កើត Digital Identity របស់អ្នក ដោយប្រើឯកសារអត្តសញ្ញាណអូស្ត្រាលីរបស់អ្នក។

3. កំណត់ myGov app PIN ថ្មី។

## ត្រូវការជំនួយឬ?

- ប្រសិនបើអ្នកត្រូវការជំនួយក្នុងការប្រើ myGov, the myGov app ឬការចុះឈ្មោះចូលក្នុង myGov, សូមហៅទូរសព្ទទៅលេខ **132 307** និងជ្រើសរើស **Option 1** សម្រាប់តុការិយាល័យជំនួយ myGov, ដែលបើកប្រតិបត្តិការចាប់ពី៖
    - ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ ម៉ោង 7:00 ព្រឹក – 10:00 យប់
    - ថ្ងៃសៅរ៍ ដល់ ថ្ងៃអាទិត្យ ម៉ោង 10:00 ព្រឹក – 5:00 ល្ងាច។
- ប្រសិនបើអ្នកស្ថិតនៅក្រៅប្រទេសអូស្ត្រាលី សូមហៅទូរសព្ទទៅលេខ **+61 1300 169 468** និងជ្រើសរើស **Option 1**។ អនុវត្តការគិតថ្លៃហៅទូរសព្ទអន្តរជាតិ។
- សម្រាប់ជំហានលម្អិតស្តីពីរបៀបភ្ជាប់សេវាកម្មនានា និងគ្រប់គ្រងគណនី myGov របស់អ្នក សូមទៅកាន់ **my.gov.au/help**
- តាមយើងនៅលើ Twitter **@myGovau**
- មើលវីដេអូ myGov នៅឯ **youtube.com/mygovau**

ចំណាំ៖ ការហៅទូរសព្ទពីទូរសព្ទផ្ទះរបស់អ្នកទៅ '13' លេខពីកន្លែងណាមួយនៅក្នុងប្រទេសអូស្ត្រាលីគឺត្រូវបានគិតថ្លៃតាមអត្រាថេរ។ អត្រានោះអាចប្រែប្រួលពីតម្លៃនៃការហៅទូរសព្ទតាមតំបន់ ហើយក៏អាចប្រែប្រួលផងដែរក្នុងចំណោមអ្នកផ្តល់សេវាទូរសព្ទនានា។ ហៅទូរសព្ទទៅលេខ '1800' ពីទូរសព្ទផ្ទះរបស់អ្នកគឺឥតគិតថ្លៃ។ ការហៅទូរសព្ទពីទូរសព្ទសាធារណៈ និងពីទូរសព្ទចល័ត អាចត្រូវបានកំណត់ម៉ោង ព្រមទាំងត្រូវបានគិតថ្លៃតាមអត្រាកាន់តែខ្ពស់។

## ការប្រកាសមិនទទួលខុសត្រូវ

ព័ត៌មានដែលមាននៅក្នុងការបោះផ្សាយនេះមានគោលបំណងតែជាការណែនាំចំពោះការបង់ប្រាក់ និងសេវាកម្មនានាប៉ុណ្ណោះ។ វាជាការទទួលខុសត្រូវរបស់អ្នកក្នុងការសម្រេចចិត្ត ប្រសិនបើអ្នកប្រាថ្នា ចង់ដាក់ពាក្យដើម្បីទទួលបានការបង់ប្រាក់ និងដើម្បីធ្វើការដាក់ពាក្យសុំទាក់ទងនឹងកាលៈទេសៈពិសេស របស់អ្នក។

# myGov app

## Secure and convenient access to myGov on your smartphone.

With the myGov app it is:

- simple to sign in
- easy to view and manage your myGov Inbox (inbox) messages
- quick to access linked services.

It also has a digital wallet to securely store some government digital cards and certificates.

## Download and set up the app

You need a myGov account to set up the app. If you do not have an account, create one at **my.gov.au**

### Downloading the app

Search for the official Australian Government myGov app in:

- Apple App Store
- Google Play.

The app is free to download and use.

### Setting up the app

Once you have downloaded the app, follow these 4 steps:

1. Open the app and select **Sign in**.
2. Read the terms of use and privacy notice. If you understand and agree with the myGov terms of use, select **I Accept**.
3. Sign in to your myGov account. You will use either:
    - your myGov sign in details (username, password and enter a security code or answer a secret question)
    - your myGovID Digital Identity, if you have created your Digital Identity using your Australian identity documents.
4. Create a myGov app PIN (personal identification number) and set your sign in option. If you have fingerprint recognition or face recognition set up on your smartphone, you will be asked if you give permission to use it to sign in.

### Rules for your myGov app PIN

Your PIN must be 6 digits long. It cannot:

- repeat the same number more than 5 times, for example 444444
- repeat pairs of numbers, for example 010101, 121212
- use numbers that are in order, for example 123456, 987654.

Do not set a **PIN** that is easy for people to guess, for example your date of birth. We recommend your myGov app PIN is different to other **PINs** you use.

# Use the myGov app

## View and manage your myGov Inbox (inbox) messages

You can:

- view, search and delete your inbox messages
- create folders and move messages between them.

## Access and manage your linked services

Use your app to quickly and securely access your myGov linked services. You can link and unlink services in the app.

## Store and access items in your myGov wallet (digital wallet)

The digital wallet is a place to securely store some government digital cards and certificates. The items you can add depend on which services you have linked and your circumstances.

You can add these items:

- Medicare cards
- Centrelink concession and health care cards.

You will be able to add more items in future.

It may take some time before all providers are ready to accept digital cards. It is a good idea to also have your physical cards with you.

Items in the wallet have a QR code (quick response code) on them. Service providers can scan this code to check the item is genuine and valid. This security feature helps protect your documents from fraud and theft.

## Change your myGov account settings

You can view and change some account settings in your app.

### Account details

You can:

- select your preferred name
- view your myGov account history
- close your myGov account.

### Sign in options

Change your sign in options, including:

- your myGov app PIN
- fingerprint recognition or face recognition.

### Notifications

You can change your notifications, including:

- turn on app push notifications
- select how you get inbox notifications
- show the service name in your inbox notification.

If you choose to get push notifications, you will need to turn on notifications in your smartphone settings. If you turn them off in your device settings, you need to update your notification preferences in your app as well.

## Get help with the app

For your app to work best, download updates as soon as they are available. You can set up automatic updates for your smartphone.

You can find help with specific tasks in the app, such as adding items to your wallet or how to change your myGov app PIN.

### If your app is not working as expected

You can:

- close the app and open it again
- turn your device off and then on again
- delete and then download the app again.

If you delete and download the app, you will need to set up your app again.

### If your device crashes or freezes

You should turn your device off and on, and check your signal or wireless internet connection.

### If you have forgotten your myGov app PIN

You can reset your myGov app PIN if you have forgotten it.

1. Select Forgot PIN on the myGov sign in screen.
2. Sign in to your myGov account. You will use either:
    - your myGov sign in details (username, password and enter a security code or answer a secret question)
    - your myGovID Digital Identity, if you have created your Digital Identity using your Australian identity documents.
3. Set a new myGov app PIN.

## Need help?

- If you need help using myGov, the myGov app or signing into myGov, call **132 307** and select **Option 1** for the myGov helpdesk, which operates from:
    - Monday to Friday 7:00am – 10:00pm
    - Saturday to Sunday 10:00am – 5:00pm.

- If you’re outside Australia, Call **+61 1300 169 468** and select **Option 1**. International call charges apply.
- For detailed steps on how to link services and manage your myGov account, go to **my.gov.au/help**
- Follow us on Twitter **@myGovau**
- Watch myGov videos at **youtube.com/mygovau**

Note: calls from your home phone to ‘13’ numbers from anywhere in Australia are charged at a fixed rate. That rate may vary from the price of a local call and may also vary between telephone service providers. Calls to ‘1800’ numbers from your home phone are free. Calls from public and mobile phones may be timed and charged at a higher rate.

## Disclaimer

The information contained in this publication is intended only as a guide to payments and services. It’s your responsibility to decide if you wish to apply for a payment and to make an application with regard to your particular circumstances.